# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ការប្រៀបធៀបសាធារណរដ្ឋប្រជាមានិតចិន និងសហរដ្ឋអាមេរិកក្នុងសង្គ្រាមកម្ពុជា ឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ។

website: www.hoksavann.org

ថ្ងៃទី២៣ សីហា ២០០៧



បន្ទាប់ពីសង្គ្រាមលោកលើកទី២ឆ្នាំ១៩៤៥មក គេសង្កេតឃើញចលនាមនោគមវិជ្ជាពីរលេចធ្លោឡើង គឺចលនាមនោគមវិជ្ជាលោកសេរី តំណាងដោយសហរដ្ឋអាមេរិក និងចលនាមនោគមវិជ្ជាកុម្មុយនិស្តតំណាងដោយសហភាពសូវៀតនិងសាធារណរដ្ឋប្រជាមានិតចិន ។ មហាអំណាចទាំងពីរក្រុមបានបង្ហាញឥទ្ធិពលរបស់ខ្លួន តាមរយៈមនោគមវិជ្ជា ដែលធ្វើឲ្យប្រទេសក្នុងពិភពលោកបែងចែកជាពីរក្រុមដែរ គឺប្រទេសកាន់របបកុម្មុយនិស្ត និងប្រទេសកាន់របបប្រជាធិបតេយ្យសេរី ។ ក្នុងចំណោមនោះមានប្រទេសជាច្រើនកាន់អព្យាក្រឹត្យ គឺមិនចូលបក្សសម្ព័ន្ធយោធាជាមួយនឹងមហាអំណាចទាំងពីរក្រុមនេះឡើយ ។ តាមការសង្កេត ប្រទេសដែលកាន់របបគ្រប់គ្រងកុម្មុយនិស្តមានចំនួនតិច ហើយប្រទេសទាំងនោះ បច្ចុប្បន្ននេះបានកែប្រែរបបសេដ្ឋកិច្ចទៅជាសេដ្ឋកិច្ចសេរី ដោយបើកឲ្យឯកជនកាន់កាប់វិញ ដូចជាចិនកុម្មុយនិស្តជាដើម ។ បន្ទាប់ពីសហភាពសូវៀតដួលរលំទៅ ប្រទេសដែលកាន់របបកុម្មុយនិស្តក៏ដួលរលំជាបន្តបន្ទាប់គ្នាដែរ ។ ឥឡូវនេះគេឈប់ប្រណាំងប្រជែងតាមមធ្យោបាយមនោគមវិជ្ជាទៀតហើយ គឺគេចាប់ផ្ដើមប្រណាំងប្រជែងគ្នាតាមមធ្យោបាយសេដ្ឋកិច្ចវិញ គឺគេធ្វើយ៉ាងណាឲ្យសេដ្ឋកិច្ចលូតលាស់ ។ ការដែលមហាអំណាចទាំងពីរក្រុមប្រណាំងប្រជែងគ្នាតាមការឃោសនាមនោគមវិជ្ជា បានធ្វើឲ្យប្រទេសតូចតាចបាក់បែកសាមគ្គីគ្នា កាប់សម្លាប់គ្នា ដោយសារតែការប្រកាន់មនោគមវិជ្ជារៀងខ្លួន ពិសេសប្រទេសនៅអាស៊ីអាគ្នេ-

យ៍ ដែលក្នុងនោះមានប្រទេសវៀតណាម កម្ពុជា និង លាវ ។ ការដែលប្រទេសតូចតាចទាំងនោះបាក់បែកគ្នា ដោយសារតែការបំរើមនោគមវិជ្ជារបស់មហាអំណាចទាំងពីរក្រុមនោះ ។

ចំពោះប្រទេសកម្ពុជា យើងសង្កេតមើល តើរបបសាធារណរដ្ឋខ្មែរដួលរលំរហូតដល់មានរបបប្រល័យពូជសាសន៍នោះតើបណ្តាលមកពីអ្វី ? សហរដ្ឋអាមេរិកគាំទ្ររបបសាធារណរដ្ឋខ្មែរ ចំណែកសាធារណរដ្ឋប្រជាមានិតចិនគាំទ្រកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ។ របបសាធារណរដ្ឋខ្មែរបានត្រូវដួលរលំនៅថ្ងៃទី១៧មេសា១៩៧៥នោះ ពុំមែនបានន័យថាពួកខ្មែរក្រហមខ្លាំងនោះទេ ប៉ុន្តែដោយសារពុំមានតុល្យភាពខាងកម្លាំងទ័ព គឺនៅថ្ងៃ១៥សីហាឆ្នាំ១៩៧៣ សភាសហរដ្ឋអាមេរិកបានអនុម័តច្បាប់ ឲ្យរដ្ឋាភិបាលអាមេរិកបញ្ឈប់ការទម្លាក់គ្រាប់បែក ព្រមទាំងហាមប្រាមមានសកម្មភាពយោធាអាមេរិកណាមួយទាំងអស់នៅឥណ្ឌូចិន ដែលនៅក្នុងនោះមានខ្មែរផង ។

ព្រះករុណាសម្តេចនរោត្តម-សីហនុ ដែលពេលនោះជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា និងជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) បានដឹងខ្លួនថា ពួកខ្មែរក្រហមមិនពេញចិត្តនឹងព្រះអង្គប៉ុន្មានទេ ហើយបើពួកនេះបានឡើងកាន់អំណាច មិនប្រាកដជាប្រគល់អំណាចឲ្យព្រះអង្គឡើយ ដូច្នេះព្រះអង្គមានបំណងបញ្ចប់សង្គ្រាមដោយការសំរុះសំរួលគ្នាកាលពីឆ្នាំ១៩៧២ និងឆ្នាំ១៩៧៣ ។ ក្នុងន័យនេះ ស្របនឹងមធ្យោបាយលោកហង់រី-គីស្ស៊ីងគ័រ រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក កាលពីថ្ងៃទី២៧ មីនា ១៩៧៣ បានស្នើទៅលោកជូ-អេនឡាយ នូវលក្ខខណ្ឌដូចតទៅ ៖ ការឈប់បាញ់ដ៏ធំមួយនៅលើដី រួមទាំងការបញ្ឈប់ការទម្លាក់គ្រាប់បែករបស់អាមេរិកផង ការចាកចេញពីប្រទេសរបស់លោកលន់-នល់ ក្នុងរយៈពេលមួយសមស្រប បន្ទាប់ពីការឈប់បាញ់គ្នាបានចូលជាធរមានហើយ ។ អ្នកឯទៀតនៅក្នុងរដ្ឋាភិបាលលន់-នល់ នៅតែស្ថិតក្នុងមុខតំណែងដដែល រង់ចាំការចរចានយោបាយ ។ រដ្ឋមន្ត្រីការបរទេសអាមេរិកនិយាយបន្តថា លោកជូ-អេនឡាយមិនបានប្រគល់លិខិតសំណើនោះ ថ្វាយសម្តេចសីហនុឡើយ បន្ទាប់ពីបានដំណឹងថា សហរដ្ឋអាមេរិកបានផ្តាច់ជំនួយគ្រប់យ៉ាង មានជំនួយយោធាជាដើមដល់សាធារណរដ្ឋខ្មែរ ដោយចិនយល់ថា កូនចៅរបស់គេ (ខ្មែរក្រហម) នឹងមានជ័យជំនះលើសាធារណរដ្ឋខ្មែរដោយកម្លាំងអាវុធ មិនចាំបាច់ចរចាសំរុះសំរួលគ្នាឡើយ ។ ដូច្នេះសំណើចរចានោះត្រូវបរាជ័យ ដោយសារសហរដ្ឋអាមេរិកផ្តាច់ជំនួយពីសាធារណរដ្ឋខ្មែរ ទន្ទឹមគ្នានឹងចិនកុម្មុយនិស្តនៅតែផ្តល់ជំនួយគ្រប់យ៉ាងដល់ខ្មែរក្រហម ។ នៅខែធ្នូ ១៩៧៤ មានការសាកល្បងឲ្យមានការចរចាម្តងទៀត ដែលផ្តួចផ្តើមគំនិតដោយប្រធានាធិបតីបារាំង Valery Giscard d'Estaing ។ គំនិតផ្តួចផ្តើមនេះ បានត្រូវបរាជ័យទៀត ។ នៅថ្ងៃទី២៦មីនា១៩៧៥ លោកគីស្ស៊ីងគ័រ រដ្ឋមន្ត្រីការបរទេសអាមេរិក បានណែនាំលោ

ក Georges Bush ដែលពេលនោះជាឯកអគ្គរដ្ឋទូតអាមេរិកប្រចាំប្រទេសចិន ឲ្យជួបសម្ដេចសីហនុហើយទូលព្រះអង្គថា សំណើដែលព្រះអង្គឲ្យជួយយកឧបករណ៍ភ្លេងនោះ (កកន ៖ ខ្សែភាពយន្ដ) សហរដ្ឋបានយកចិត្តទុកដាក់ ហើយសូមទូលសួរព្រះអង្គថា តើព្រះអង្គត្រូវបញ្ចប់នូវសោកនាដកម្មរបស់ខ្មែររបៀបណា ។ សម្ដេចសីហនុដំបូងហាក់ដូចជាយល់ស្រប នូវសំណើដែលថា ឲ្យព្រះអង្គយាងទៅធ្វើប្រមុខរដ្ឋអព្យាក្រឹត្យនៅភ្នំពេញ សំរុះសំរួលកុំឲ្យខ្មែរក្រហមមានអំណាចតែម្នាក់ឯងផង ហើយមន្ត្រីរដ្ឋការលន់-នល់ឲ្យធ្វើការដូចធម្មតា វៀរលែងតែលោកលន់-នល់ត្រូវចាកចេញពីប្រទេស ។ ប៉ុន្តែមធ្យោបាយនេះពុំអាចអនុវត្តទៅបានឡើយ ព្រោះយោធាខ្មែរក្រហមមានជ័យជំនះស្ទើរគ្រប់សមរភូមិ ជាពិសេសនៅដើមឆ្នាំ១៩៧៥ បានផ្លោងគ្រាប់បែកចូលមកវាលយន្តហោះពោធិចិនតុងម្ដងៗផង ដូច្នេះសំណើរនេះត្រូវហួសពេល ទើបសម្ដេចសីហនុងាកមករកខ្មែរក្រហមវិញ សំណើនោះក៏ត្រូវបរាជ័យ ។ ក៏ដូចគ្នានឹងសំណើរបស់ប្រធានាធិបតីបារាំងក៏ត្រូវបរាជ័យ ដោយសារតែចិនកុម្មុយនិស្តពុំទទួលប្រេសិតរបស់លោកប្រធានាធិបតី ដែលបញ្ជូនឲ្យយកសំណើទៅថ្វាយសម្ដេចសីហនុ ។

ផ្ទុយទៅវិញ លោក John Gunther Dean ជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំសាធារណរដ្ឋខ្មែរ ជាចុងក្រោយ ថ្ងៃ៣១មីនា១៩៧៤ តាមឯកសាររាប់ពាន់ក្បាល ដែលលោក Dean ប្រគល់ឲ្យបណ្ណាល័យ Jimmy Carter នៅក្រុង Atlanta រដ្ឋ Georgia ក្នុងឯកសារនោះ លោក Dean បន្ទោសលោកគីស្ស៊ីងគ័រ ចំពោះបរាជ័យរបស់លោក ចំពោះសំណើចរចាជាមួយសម្ដេចសីហនុនិងខ្មែរក្រហម ដើម្បីបញ្ចប់សង្គ្រាមប្រទេសកម្ពុជា ព្រោះលោកគីស្ស៊ីងគ័រពេលនោះជាមន្ត្រីជាន់ខ្ពស់ដ៏មានអំណាចម្នាក់នៅក្នុងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក ។ នៅឆ្នាំ១៩៧៤ លោកហ្វីលីព-ហាប៊ីត ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសនៃសហរដ្ឋអាមេរិកសំរាប់អាស៊ី-បូព៌ា រួមជាមួយលោក Dean បានព្រាងអនុស្សារណៈជាសម្ងាត់មួយ សំរាប់សន្និសិទអន្តរជាតិដើម្បីបញ្ចប់សង្គ្រាមកម្ពុជា បញ្ជូនទៅលោកគីស្ស៊ីងគ័រ ប៉ុន្តែពុំមានចម្លើយជាវិជ្ជមានឡើយ ។ លោកគីស្ស៊ីងគ័រដោះសារថា ពួកកុម្មុយនិស្តខ្មែរក្រហមធ្វើឲ្យរាំងស្ទះដំណើរចរចា ព្រោះពួកគេចង់ដណ្ដើមយកអំណាចដោយចុងអាវុធ ឯសម្ដេចសីហនុវិញ ព្រះអង្គមិនអាចជួយដោះស្រាយតាមផ្លូវនយោបាយបានឡើយ ។ តាំងពីលោកធ្វើឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាពីឆ្នាំ១៩៧៤ដល់ដើមឆ្នាំ១៩៧៥ លោក Dean តែងតែធ្វើរបាយការណ៍អំពីគ្រោះថ្នាក់នៃសាធារណរដ្ឋខ្មែរ ជាមួយនឹងសំណើរបស់លោក សុំឲ្យមានការចរចាជាមួយសម្ដេចសីហនុ ជូនទៅរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ ប៉ុន្តែពុំមានចម្លើយណាមួយស្របតាមសំណូមពររបស់លោកឡើយ ។ សហរដ្ឋអាមេរិកនៅតែផ្ដល់ជំនួយបន្តិចបន្តួចឲ្យដល់សាធារណរដ្ឋខ្មែរ ហាក់ដូចជាបន្តក់ទឹកឲ្យបុគ្គលដែលជិតស្លាប់ប៉ុណ្ណោះ ហើយសហរដ្ឋអាមេរិក

មិនបានគិតគូរពីគ្រោះថ្នាក់របស់សាធារណរដ្ឋខ្មែរ ពេលខ្មែរក្រហមដឹឃោរឃៅឡើងកាន់អំណាចឡើយ ។ នៅពេលដែលខ្មែរក្រហមមានប្រៀបខាងកម្លាំងទ័ពទៅលើសាធារណរដ្ឋខ្មែរ សម្ដេចសីហនុបានធ្វើសេចក្ដីថ្លែងការណ៍ដ៏មឺុងម៉ាត់មួយ គំរាមសម្លាប់រដ្ឋាភិបាល លន់-នល់ ហើយព្រះអង្គច្រានចោលនូវកិច្ចចរចាសំរុះសំរួលនាទីចុងក្រោយណាមួយ ដែលព្រះអង្គចាត់ទុកថា ជា«កលល្បិចនយោបាយ» ។ លោក Dean យល់ថាកិច្ចចរចាអាចជៀសវាងមិនឲ្យមានទីបញ្ចប់ដ៏សាហាវមួយ សំរាប់សង្គ្រាមនៅកម្ពុជា ដោយហោចណាស់ ក៏មិនមែននាំទៅរកការប្រគល់ខ្មែរដែលគ្មានអ្វីការពារខ្លួន ទៅឲ្យពួកខ្មែរក្រហមដែរ ។ លោក Dean បានចាកចេញពីប្រទេសកម្ពុជា ដោយសេចក្ដីក្រៀមក្រំជាទីបំផុត ព្រោះលោកមិនបានជួយប្រជាពលរដ្ឋខ្មែរបាន នៅថ្ងៃ១២មេសា១៩៧៥ម៉ោង៨ព្រឹក ជនជាតិអាមេរិកាំង៨២នាក់ ជនជាតិខ្មែរ១៥៩នាក់ និងជនជាតិផ្សេងៗចំនួន៣៥នាក់ ត្រូវបានជន្លៀសចេញតែក្នុងរយៈពេលមិនដល់ពីរម៉ោងផង ។

សារនានាបានត្រូវបញ្ជូនទៅឲ្យអ្នកដឹកនាំកំពូលនៃកម្ពុជា ដើម្បីទទួលជន្លៀសចេញពីកម្ពុជា ប៉ុន្ដែភាគច្រើនបានប្រកែក ដូចជាលោកលន់-ណុន និងលោកឡុង-បូរ៉េតជាដើម ហើយនិយាយចំអកឲ្យអាមេរិកាំងទៀតផង ។ សិរិមតៈ ជាអតីតនាយករដ្ឋមន្ត្រីបានឆ្លើយតបទៅលោក Dean ដូចតទៅនេះ ៖

«ជូនឯកឧត្តមនិងមិត្តសំឡាញ់

«ខ្ញុំសូមអរគុណយ៉ាងស្មោះ ចំពោះលិខិតរបស់ឯកឧត្តម ហើយនិងសំណើរបស់ឯកឧត្តម ក្នុងការដឹកជញ្ជូនខ្ញុំទៅរកសេរីភាព ។ ជាការគួរឲ្យស្ដាយ ដែលខ្ញុំមិនអាចចាកចេញក្នុងបែបកំសាករបៀបនេះបានទេ ។ ចំពោះរូបលោក ក៏ដូចជាចំពោះមហាប្រទេសរបស់លោកដែរ ខ្ញុំមិនដែលជឿមួយខណៈណាឡើយថា លោកអាចបោះបង់ប្រជាជនមួយ ដែលបានជ្រើសរើសយកសេរីភាពនោះសោះទេ ។ លោកបានប្រកែកមិនព្រមផ្ដល់នូវកិច្ចគាំពារចំពោះពួកយើង ហើយយើងក៏មិនអាចធ្វើអ្វីកើតលើប្រការនេះឡើយ ។

លោកចាកចេញទៅហើយ ៗខ្ញុំសូមជូនពរលោក សូមលោកនិងប្រទេសរបស់លោក រកឃើញសុភមង្គលនៅក្រោមនភាល័យនេះចុះ ។ តែសូមលោកចាំឲ្យច្បាស់ថា ប្រសិនបើខ្ញុំត្រូវស្លាប់នៅទីនេះ និងនៅក្នុងប្រទេសដែលខ្ញុំស្រឡាញ់ នេះក៏មិនជាបញ្ហាអ្វីដែរ ព្រោះយើងសុទ្ធតែកើតហើយស្លាប់ទាំងអស់គ្នា ។ ខ្ញុំបានធ្វើការភ័ន្តច្រឡំតែមួយគត់ គឺបានជឿលើពួកលោក ។

«សូមឯកឧត្តម និងមិត្តមេត្តា ទទួលនូវមនោសញ្ចេតនាដ៏ស្មោះ និងជាមិត្តភាពអំពីខ្ញុំ» ។

ពួកខ្មែរក្រហមបានកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃ១៧មេសា១៩៧៥ ។ លោកឡុង-បូរ៉េតត្រូវប្រហារជីវិតភ្លាម ជាមួយនិងសមាជិករដ្ឋាភិបាលខ្លះទៀត ។ អតីតបុគ្គលិករដ្ឋ

ទាំងអស់ព្រមទាំងគ្រួសារ ត្រូវបានប្រហារជីវិតនៅថ្ងៃបន្តបន្ទាប់មកទៀត ។ ពលរដ្ឋខ្មែរពីរលាននាក់បានត្រូវបញ្ចេញចេញពីភ្នំពេញ ។ ពលរដ្ឋខ្មែរពីរលាននាក់បានត្រូវសម្លាប់ ។ សិរិមតៈត្រូវខ្មែរក្រហមបាញ់ត្រូវពោះ ហើយត្រូវគេទុកចោល ។ លោកត្រដិរខ្យល់បីថ្ងៃទើបទទួលមរណភាព ។

ផ្ទុយពីសហរដ្ឋអាមេរិក បងប្អូនខ្មែរជ្រាបហើយ ចិនជួយខ្មែរក្រហមចប់ចុងចប់ដើម ជួយមិនឈប់ មិនដូចសហរដ្ឋអាមេរិក ជួយរហូតដល់ឈ្នះសាធារណរដ្ឋខ្មែរ ។ មិនតែប៉ុណ្ណោះ ពេលដែលកូនចៅគេ(ខ្មែរក្រហម) ចាញ់កងទ័ពវៀតណាមឆ្នាំ១៩៧៩ និងមានសង្គ្រាមមកទៀតចាញ់ទៀត ចិននៅតែជួយមិនឲ្យកូនចៅគេស្លាប់ បញ្ជូនកូនចៅទៅសមាហរណកម្មកងទ័ពជាមួយបក្សប្រជាជនកម្ពុជា ។ ដូច្នេះ ពេលខ្មែរក្រហមមានជ័យជំនះ ចិននៅជាមួយខ្មែរក្រហម ពេលខ្មែរក្រហមចាញ់មានទុក្ខ ចិនក៏មិនរត់ចោលខ្មែរក្រហម ខំជួយដោះស្រាយសេចក្តីទុក្ខនេះ ។ នេះបានចំជាឪពុកម្តាយរួមសុខរួមទុក្ខជាមួយកូនពិតមែន ។

សូមជនរួមជាតិពិនិត្យមើលអាកប្បកិរិយារបស់សហរដ្ឋអាមេរិកទៅលើប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ដែលជាដំបូងយើងសូមដកស្រង់យកពាក្យលោក Dean ដែលជាទូតអាមេរិកចុងក្រោយបានថ្លែងក្នុងពេលថ្មីៗនេះថា អ្នកដឹកនាំបច្ចុប្បន្នគួររៀនមេរៀនអំពីដំណោះស្រាយដ៏មិនស្ងប់មួយ ដែលគេមិនអាចត្រួតត្រាបាន សំរាប់វិបត្តិនៅប្រទេសកម្ពុជា ។ ការគ្រាន់តែដកទ័ពរបស់យើងចេញ មិនជាការគ្រប់គ្រាន់ទេ យើងត្រូវរកទីបញ្ចប់មួយ ដែលប្រហែលជាមិនល្អសំរាប់យើង តែវាអាចបង្ហាញឲ្យយើញថា យើងមានកង្វល់និងការយកចិត្តទុកដាក់ចំពោះអ្នកដទៃទៀតដែរ ។ ជាពិសេសមនុស្សទាំងអស់ដែលផ្សងវាសនារបស់គេជាមួយយើង ។ នៅទីកន្លែងណាក៏ដោយ ដែលមានភាគីច្រើនប្រកាន់យកគំនិតខុសគ្នា ហើយធ្វើការវាយប្រយុទ្ធគ្នា គឺកន្លែងនោះពិតជាអាចទទួលផលកម្រៃពីមេរៀនប្រទេសកម្ពុជាឆ្នាំ១៩៧០ពុំខានឡើយ ។ ត្រង់នេះលោក Dean ចង់បញ្ជាក់ថា សហរដ្ឋអាមេរិកមិនគួររត់ចោលប្រជាពលរដ្ឋខ្មែរ ទុកឲ្យខ្មែរក្រហមសម្លាប់ នៅពេលដែលពលរដ្ឋខ្មែរប្រឆាំងនឹងកុម្មុយនិស្ត ដែលជាសត្រូវរបស់សហរដ្ឋអាមេរិកដូច្នេះឡើយ ។ មួយទៀត តាមសំដីលោកសិរិមតៈថា «ខ្ញុំបានធ្វើការភ័ន្តច្រឡំតែមួយគត់ គឺបានជឿលើពួកលោក» បានសេចក្តីថា អាមេរិកាំងជាមិត្តក្បត់ ជាមិត្តក្បត់មិត្ត ជាមិត្តមិនស្មោះត្រង់ដែលគួរទុកចិត្តបាន មិត្តរត់ចោលមិត្តដែលមានទុក្ខ ។ ដូចជាឲ្យឈ្លោះនឹងខ្លា ហើយរត់ចោលជំរុញឲ្យខ្លាទំពារស៊ី ។ វិបត្តិប្រទេសកម្ពុជាចេញមកពីសង្គ្រាមវៀតណាម ដែលអាមេរិកប្រឆាំងនឹងពួកកុម្មុយនិស្ត ធ្វើឲ្យកងទ័ពយៀកកុងនិងយួនខាងជើងចូលមកដីខ្មែរ ដែលធ្វើឲ្យមានទម្លាក់សម្តេចសីហនុនៅប្រទេសកម្ពុជា ។ ជាសក្ខីកម្ម លោកប្រធានាធិបតីនិចសុន មុនលាចេញពីតំណែង បានទទួលសារភាពអំពី

ប្រតិបត្តិការសម្ងាត់នៅក្នុងប្រទេសកម្ពុជា ដែលអ្នកប្រវត្តិសាស្ត្រខ្លះនិយាយថា ជាអណ្តាតភ្លើងដែលបានដុតឲ្យឆាបឆេះ ដល់ការបះបោររបស់ពួកកុម្មុយនិស្តនៅប្រទេសកម្ពុជា ។

ដូច្នេះវិបត្តិកម្ពុជាទាក់ទងនឹងសហរដ្ឋអាមេរិក មិនគួរអាមេរិករត់ចោលទុកឲ្យខ្មែរស្លាប់ គឺអាមេរិកគិតតែប្រយោជន៍ផ្ទាល់ខ្លួន មិនគិតពីប្រយោជន៍អ្នកដទៃដែលជាមិត្តរបស់ខ្លួន ។ អាមេរិកមុននឹងចាកចេញពីឥណ្ឌូចិន ជាពិសេសពីកម្ពុជា អាមេរិកត្រូវតែរកដំណោះស្រាយតាមផ្លូវនយោបាយ ឆ្លងតាមការចរចាសំរុះសំរួមជាមួយសម្តេចសីហនុនិងខ្មែរក្រហម ដើម្បីកុំឲ្យមានការកាប់សម្លាប់គ្នា ។ ប៉ុន្តែរដ្ឋការវ៉ាស៊ិនតោនបានព្រងើយកន្តើយចំពោះសំណើឲ្យមានការបញ្ចប់សង្គ្រាមក្នុងប្រទេសកម្ពុជា ដូចសំដីលោក Dean បានបញ្ជាក់ ។ មិនតែប៉ុណ្ណោះ អាមេរិកបានបន្ថយជំនួយពីសាធារណរដ្ឋខ្មែរបន្តិចម្តងៗ ធ្វើឲ្យសាធារណរដ្ឋនេះកាន់តែខ្សោយទៅៗ ជំរុញឲ្យពួកកុម្មុយនិស្តមានកម្លាំងកាន់តែខ្លាំងឡើងៗ រហូតយកជ័យជំនះនៅទីបំផុត កើតបានជាវាលពិឃាតដូច្នេះទៅ ។ មួយទៀត ដើម្បីការចរចាមានប្រសិទ្ធិភាព លុះត្រាតែអាមេរិកនៅតែផ្តល់ជំនួយយោធានិងសេដ្ឋកិច្ចឲ្យដល់សាធារណរដ្ឋខ្មែរ ឲ្យមានតុល្យភាពខាងកម្លាំង ទើបសត្រូវម្ខាងទៀតព្រមចរចា សមដូចពាក្យលោក Dean ពោលថា នយោបាយការទូតគេត្រូវយកទៅប្រើ នៅពេលដែលភាគីម្ខាងទៀតមិនទាន់បានទទួលជ័យជំនះ មិនមែនចាំមនុស្សឃោរឃៅមកដល់ក្លោងទ្វារហើយ ទើបយកនយោបាយទូតទៅប្រើនោះឡើយ ។ អាមេរិកបានធ្វើកំហុសមួយយ៉ាងធ្ងន់នៅប្រទេសកម្ពុជានាឆ្នាំ១៩៧០ ដែលផ្តួយនឹងចិនកុម្មុយនិស្ត គេជួយកូនចៅគេចប់ចុងចប់ដើម ។ នេះជាមេរៀនប្រវត្តិសាស្ត្រ ដែលប្រជាពលរដ្ឋខ្មែរតែចងចាំថា ប្រទេសណាក៏ដោយ គេគិតពីប្រយោជន៍ប្រទេសគេ មុនប្រយោជន៍ប្រទេសយើងជាការពិតណាស់ ។ បើគេឃើញប្រយោជន៍ប្រទេសគេហើយ គេចាប់អនុវត្តភ្លាម ទោះបីការអនុវត្តន៍នោះត្រូវស្លាប់ប្រទេសយើងក៏ដោយ ។ ដូច្នេះសូមខ្មែររួបរួមគ្នា ដោះស្រាយបញ្ហាខ្លួនដោយខ្លួនឯង ។៚

❄ ❄

❄